ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ....................................

# ការបំភ្លឺរបស់ក្រសួងរ៉ែ និងថាមពល
# លើគម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែង

-សន្និសីទរៀបចំឡើងដើម្បីបំភ្លឺចំពោះការបំផ្លោងពាក្យខុសពីការពិត អំពីគម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែង ដូចជា បំផ្លោងពាក្យបំផ្លើសថាគម្រោងនេះធ្វើឲ្យខូចខាតធ្ងន់ធ្ងរដល់ព្រៃឈើ សត្វព្រៃ ត្រី ក្រពើ ទំនៀមទម្លាប់ប្រពៃណីជនជាតិ ។ល។ គឺហាក់ដូចជាគម្រោងវារីអគ្គិសនីនេះកំពុងត្រូវបានអភិវឌ្ឍន៍នៅលើទីតាំងនោះ កំពុងកាប់បំផ្លាញព្រៃឈើរាប់ម៉ឺនហិកតា។ល។ ដែលតាមការពិតគម្រោងស្ថិតក្នុងដំណាក់កាលសិក្សានៅឡើយ។

-ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៤ ក្រសួងរ៉ែ និងថាមពល បានចេញផ្សាយការបំភ្លឺតាមប្រព័ន្ធសារព័ត៌មានរួចហើយ ប៉ុន្តែក្រសួងពិនិត្យឃើញមានការចាំបាច់ត្រូវបំភ្លឺផ្ទាល់ចំពោះមុខអ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាបន្ថែមទៀត។

-គម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែង ត្រូវបានកំណត់សម្រាប់ការអភិវឌ្ឍតាំងពីមុនឆ្នាំ១៩៧០ ជាមួយគម្រោងវារីអគ្គិសនីដទៃទៀតនៅភាគខាងលិច ដូចជា វារីអគ្គិសនីគីរីរម្យ(មាន៣) កំចាយ អាតៃ ឫស្សីជ្រុំ (មាន៣) តាតៃ មេទឹក ពោធិ៍សាត់(មាន២) បាត់ដំបង(មាន២) និងគម្រោងនានាក្នុងអាងទន្លេមេគង្គ ដែលមានសក្តានុពលសម្រាប់អភិវឌ្ឍន៍។

-គម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែង មានទីតាំងស្ថិតនៅលើស្ទឹងជាយអារ៉ែង ក្នុងស្រុកថ្មបាំង ខេត្តកោះកុង មានចម្ងាយគិតតាមផ្លូវប្រមាណ ២០ គីឡូម៉ែត្រ (គិតតាមកាត់ត្រង់ប្រមាណ ១២គីឡូម៉ែត្រ) ខាងកើតឈៀងខាងត្បូងទីរួមស្រុកថ្មបាំង។

-ការសិក្សាបច្ចេកទេស និងបរិស្ថានធម្មជាតិ និងសង្គម បានចាប់ផ្តើមតាំងពីឆ្នាំ២០០៦។ នៅខែវិច្ឆិកា-ធ្នូ ឆ្នាំ២០១៣ មានការផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមដំបូង (ESIA) មានដូចខាងក្រោម ៖

១-ការប៉ះពាល់ព្រៃឈើ

តំបន់ជាយអារ៉ែងមានផ្ទៃដីប្រមាណជាង ១០ម៉ឺន ហិកតា ។ ផ្ទៃដីដែលត្រូវការសម្រាប់ធ្វើអាងទឹកនៃគម្រោងមានប្រមាណ ៩៤៧៤ ហិកតា ដែលក្នុងនោះមានព្រៃស្រោងប្រមាណ ៨៧៤ ហិកតា និងព្រៃពាក់កណ្តាលស្រោងប្រមាណ ៣៧៩០ ហិកតា ក្រៅពីនោះ រួមមាន៖

| | | |
|---|---|---|
| -ព្រៃអ្នកតា | ៦៦ | ហិកតា |
| -ព្រៃល្បោះ | ៣៧ | ហិកតា |
| -ព្រៃដុះឡើងវិញ | ៧២៨ | ហិកតា |
| -ព្រៃកប់ខ្មោច | ១៣ | ហិកតា |
| -វាលស្មៅ | ៤៨៧ | ហិកតា |
| -ផ្ទៃទឹក | ១៥៦ | ហិកតា |
| -វាលស្រែ | ១១៩៤ | ហិកតា |
| -ដីចំការ | ១២៩៥ | ហិកតា |
| -ដីកសិកម្មបោះបង់ចោល | ៧០៥ | ហិកតា |
| -ដីលំនៅដ្ឋាន | ១២៩ | ហិកតា |

២-ការប៉ះពាល់សត្វ

ការសិក្សាផលប៉ះពាល់ដំហិានដំបូងបានរកឃើញថា នៅតំបន់ដាយអារ៉ែង មានបក្សីប្រមាណ ១១៣ ប្រភេទ ថនិកសត្វ ៥៣ ប្រភេទ ល្មូន ៣១ ប្រភេទ និងមច្ឆាជាតិ ៤៣ ប្រភេទ។ ការសិក្សាជំហានបន្ទាប់នឹងពិនិត្យអំពីលក្ខខ័ណ្ឌរស់នៅ និងចរាចរណ៍របស់សត្វទាំងនោះ ដើម្បីរកវិធីធ្វើការអភិរក្ស និងកាត់បន្ថយផលប៉ះពាល់ឲ្យនៅតិចបំផុត មិនត្រឹមតែសម្រាប់ត្រីនាគ ត្រីខ្មៅ ឬក្រពើភ្នំប៉ុណ្ណោះទេ។ ការសិក្សាជំហានបន្ទាប់នេះនៅមិនទាន់អាចចាប់ផ្តើមនៅឡើយទេ។

៣-ផលដែលទទួលបានពីគម្រោង

ពិតមែនតែគម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែងមានអានុភាពតម្លើងត្រឹម ១០៨មេហ្គាវ៉ាត់ ប៉ុន្តែវារីអគ្គិសនីនេះអាចដំណើរការស្ទើរពេញមួយឆ្នាំ ដែលបរិមាណថាមពលផលិតបានប្រចាំឆ្នាំមានរហូតដល់ ៩៩៥ លានគីឡូវ៉ាត់ម៉ោង ច្រើនជាងវារីអគ្គិសនីកំចាយដែលផលិតបានតែ ៤៩៨ លានគីឡូវ៉ាត់ម៉ោង ទោះជាមានអានុភាពតម្លើងធំជាងដល់ទៅ ១៩៤ មេហ្គាវ៉ាត់ ក៏ដោយ។ ទន្ទឹមនោះ គម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែងក៏ដូចវារីអគ្គិសនីដទៃទៀតដែរនឹងទទួលបានអត្ថប្រយោជន៍ជាច្រើនទៀត ដូចជា៖

- ធានាសន្តិសុខថាមពល ធានានូវស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់
- ការពារទឹកជំនន់
- ថាមពលអគ្គិសនីជាពីគម្រោងនេះមានថ្លៃថោរ និងថោកជាងការផលិតដោយប្រេងឥន្ធនៈធ្យូងថ្ម សូឡា និងការនាំចូលពីក្រៅប្រទេស
- ទទួលបានប្រាក់ចំណូលពន្ធពីការវិនិយោគគម្រោង
- អាចចែកចាយ និងផ្គត់ផ្គង់ថាមពលអគ្គិសនីទូទាំងប្រទេសតាមប្រព័ន្ធបណ្តាញបញ្ជូនជាតិ
- ជារមណីយដ្ឋានទេសចរណ៍ធម្មជាតិ (អេកូទេសចរណ៍)

- កាត់បន្ថយភាពក្រីក្រដល់ប្រជាពលរដ្ឋតាមរយៈនៃការបង្កើតការងារជូនពួកគាត់ក្នុងអំឡុងពេលនៃការសាងសង់ និងដំណើរការគម្រោង
- ជួយកាត់បន្ថយការប្រើប្រាស់អុស ធ្យូង
- លើកកំពស់សមភាពយេនឌ័រក្នុងសង្គម
- កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងទទួលបានឥណទានកាបូន (Carbon Gredit) អាចលក់បាននៅលើទីផ្សារអន្តរជាតិ
- ជួយបណ្តុះបណ្តាលប្រព័ន្ធវារីវប្បកម្ម បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងចិញ្ចឹមត្រីជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគម្រោង
- ជាកន្លែងសិក្សាស្រាវជ្រាវរបស់និស្សិត
- ទទួលបានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា បណ្តាញអគ្គិសនី សាលារៀន មណ្ឌលសុខភាព វត្តអារាម ផ្លូវថ្នល់ ស្ពាន ជាដើម ។ល។

៤-ផលប៉ះពាល់ប្រជាពលរដ្ឋនៅតំបន់គម្រោង

ការសិក្សាជំហ៊ានដំបូងនៅខែវិច្ឆិកា-ធ្នូ ឆ្នាំ២០១៣ អំពីផលប៉ះពាល់សង្គមដោយសារគម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែង បានរកឃើញថា គម្រោងនេះការប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ១៣១៨នាក់ (ស្រីមានចំនួន ៦៣៧នាក់) ត្រូវជា ៣៤៩ គ្រួសារ នៅក្នុង ០៣ ឃុំ ស្មើនឹង ០៧ ភូមិ ដែលមានចំនួនខ្នងផ្ទះសរុប ៣៣១ នៅក្នុងនោះ រួមមាន៖

- ឃុំជំនាប់ មានចំនួន ៩៦ ខ្នងផ្ទះ គឺ៖ ភូមិជំនាប់ ៥៦ ខ្នងផ្ទះ និងភូមិប្រកឫស្សី ៤០ ខ្នងផ្ទះ។
- ឃុំប្រឡាយ មានចំនួន ១៨៧ ខ្នងផ្ទះ គឺ៖ ភូមិប្រឡាយ ៥៣ ខ្នងផ្ទះ ភូមិតាងិល ២៨ ខ្នងផ្ទះ ភូមិសំរោង ៦៤ ខ្នងផ្ទះ និងភូមិចំណារ ៤២ ខ្នងផ្ទះ។
- ឃុំថ្មដូនពៅ មានចំនួន ៤៨ ខ្នងផ្ទះ គឺ៖ ភូមិព្រែកស្វាយ ៤៨ ខ្នងផ្ទះ។

ទន្ទឹមនោះក៏មានប៉ះពាល់សាលារៀនចំនួន ០៦ វត្តអារាមចំនួន ០៣ ស្រះទឹកសហគមន៍ចំនួន ០៦ សាលាឃុំចំនួន ០២ ជង្រុកស្រូវសរុបចំនួន ៦៥ ទ្រុងមាន់ទានិងក្រោលសត្វពាហនៈចំនួន ២០៥ ហាងឬតូបលក់ទំនិញចំនួន ១៥ និងសំណង់ផ្សេងៗទៀត ដូចជា របង ផ្នូរខ្មោច អណ្តូងទឹក ។ល។

ចំពោះការដោះស្រាយគឺ គ្រប់គម្រោងវារីអគ្គិសនីត្រូវមានការសិក្សាលម្អិតអំពីផលប៉ះពាល់បរិស្ថាន និងសង្គម និងផែនការនៃការដោះស្រាយផលប៉ះពាល់ទាំងនោះ។ បច្ចុប្បន្ន អ្នកសិក្សាជំហ៊ានបន្ទាប់នៃគម្រោងវារីអគ្គិសនីស្ទឹងជាយអារ៉ែង កំពុងព្យាយាមចុះទៅសិក្សាលម្អិតនៅតំបន់នោះ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤